NSW ក្រសួងអប់រំ រដ្ឋ

# ដំបូន្មានទាន់បច្ចុប្បន្នភាពស្តីពី COVID-19 (ជំងឺខូវីដ-១៩)

NSW Health (សុខាភិបាលរដ្ឋ) NSW) បានចេញដំបូន្មានថ្មីសម្រាប់សាលារៀនកាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០។ ដំបូន្មានថ្មីនេះ ផ្លាស់ប្តូររបៀបដែលសាលារៀនរបស់យើងដំណើរការ។

1. កុមារដែលឈឺមានរោគសញ្ញាដូចជាគ្រុនផ្តាសាយ ទោះបីជារោគសញ្ញាទាំងនោះស្រាលក៏ដោយ គួរតែស្នាក់នៅផ្ទះ។ កុមារដែលធ្លាក់ខ្លួនឈឺនៅសាលារៀន នឹងត្រូវបានរក្សាទុកនៅកន្លែងថែទាំមនុស្សឈឺ ហើយការរៀបចំនឹងត្រូវបានធ្វើឡើងដើម្បីមកយកពួកគេពីសាលារៀន។
    - សុខាភិបាលរដ្ឋ NSW បានស្នើសុំឱ្យសាលារៀនលើកទឹកចិត្តនរណាម្នាក់ដែលមិនស្រួលខ្លួន ឬទោះបីជាមានរោគសញ្ញាស្រាលដូចគ្រុនផ្តាសាយក្តី ដើម្បីរៀបចំធ្វើតេស្តតាមរយៈអ្នកព្យាបាលតាមតំបន់របស់ពួកគេ ឬតាមរយៈ COVID-19 clinics (គ្លីនិក) ណាមួយ។
    - សិស្ស និងបុគ្គលិកដែលមានរោគសញ្ញាដូចជំងឺគ្រុនផ្តាសាយ នឹងចាំបាច់ត្រូវប្រគល់លទ្ធផលនៃការធ្វើតេស្ត COVID-19 អវិជ្ជមាន មុនពេលត្រូវបានអនុញ្ញាតឱ្យចូលសាលារៀនវិញ។
2. ពេលណាដែលអាចធ្វើទៅបាន សិស្សនឹងស្នាក់នៅក្នុងក្រុមរបស់ពួកគេ (ពោលគឺថ្នាក់ ក្រុមកម្រិតថ្នាក់ ឬដំណាក់កាល) សម្រាប់សកម្មភាពរៀនសូត្រទាំងអស់នៅក្នុងសាលារៀនរបស់ពួកគេ ដើម្បីកំណត់ទំនាក់ទំនងជិតស្និទ្ធ។
3. ការធ្វើទស្សនកិច្ចសាលាដែលមិនសំខាន់ មិនបានអនុញ្ញាតទេ។ ប្រសិនបើអ្នកចង់និយាយជាមួយគ្រូបង្រៀន ឬសមាជិកបុគ្គលិកនៅសាលារៀន អ្នកគួរតែទូរស័ព្ទទៅសាលារៀន ហើយធ្វើការណាត់ជួប។ ការណាត់ជួបនឹងត្រូវធ្វើឡើងតាមទូរស័ព្ទ ឬតាមរយៈការធ្វើសន្និសិទវីដេអូ។
4. សកម្មភាពអន្តរសាលាត្រូវតែស្ថិតនៅក្នុងសហគមន៍ ឬមណ្ឌល។ សកម្មភាពប្រកួតកីឡា ឬសកម្មភាពប្រហាក់ប្រហែលគ្នាដែលមានការជួបជុំធំៗ ដែលទាក់ទិនសាលារៀនច្រើនជាងពីរ មិនបានអនុញ្ញាតទេ។
5. រាល់ការច្រៀងជាក្រុម (ក្រុមចម្រៀង) និង/ ឬសកម្មភាពច្រៀងចម្រៀងផ្សេងទៀត ក៏ដូចជាការប្រើប្រាស់ឧបករណ៍ត្រែ (wind instrument) ជាក្រុម មិនបានអនុញ្ញាតទេ។ ការរៀបចំពិសេសត្រូវបានដាក់នៅនឹងកន្លែង សម្រាប់សិស្សវិញ្ញាបនបត្រមធ្យមសិក្សា (HSC)។
6. សិស្ស Year 11 និង Year 12 ដែលកំពុងបញ្ចប់មុខវិជ្ជា (HSC) អាចបន្តមកថ្នាក់រៀន/សកម្មភាពទាក់ទងនឹងមុខវិជ្ជាដែលមាននៅតាមសាខាផ្សេងទៀតតែប៉ុណ្ណោះ។ សិស្សផ្សេងទៀតទាំងអស់ រួមទាំងសិស្ស Year 11 ដែលមិន បញ្ចប់មុខវិជ្ជា HSC មិនត្រូវទៅសាខាសាលាផ្សេងទៀតសម្រាប់ Term 3 ដែលនៅសេសសល់ឡើយ។ កម្មវិធី TAFE និង VET ផ្សេងទៀតអាចបន្តបាន។

ទោះបីជាកម្មវិធីបង្ហាញណែនាំមត្តេយ្យសាលាសម្រាប់ឆ្នាំ២០២១ នៅតែផ្អាកដំណើរការក្តី មានការឱ្យយោបល់ល្អៗដែលអាចរកបាន តាមរយៈ department's website (វិបសៃថ៍របស់ក្រសួង)។ យោបល់ទាំងនេះនឹងជួយរក្សាឱ្យសិស្សរំភើបចិត្ត ហើយទាក់ទិនសម្រាប់ការផ្លាស់ប្តូររបស់ពួកគេចូលទៅមត្តេយ្យសាលា។.

សូមធ្វើការណាត់ជួបជាមួយសាលារៀនរបស់អ្នក ដើម្បីស្វែងយល់បន្ថែមអំពីការផ្លាស់ប្តូរទាំងនេះ។

## សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែមទៀត សូមទូរស័ព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅ សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ សេវាកម្មនេះនឹងមិនគិតថ្លៃពីអ្នកទេ។